ការសម្ភាសរបស់អ្នកមីង ទឹម រុន

កៈ អ្នកសម្ភាសឈ្មោះ ញ៉ែម សុគន្ធា   ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ ទឹម រុន

កៈ ចឹងនាងខ្ញុំសូមចាប់ផ្តើមធ្វើការសម្ភាសដល់អ៊ុំស្រីតែម្តង ហើយការសម្ភាសនេះត្រូវបានរៀបចំឡើងដោយសាកលវិទ្យាល័យនៅប្រទេសអាមេរិច ឈ្មោះថា ប៊ី វ៉ាយ យូ។ ចឹងពួកយើងនឹងដាក់ការសម្ភាសមួយនេះចូលទៅក្នុងសាកលវិទ្យាល័យរបស់វេបសាយរបស់សកលវិទ្យាល័យហ្នឹង។ ចឹងអ៊ុំស្រីតើអ៊ុំស្រីឈ្មោះពេញ ឈ្មោះអីគេដែរអ៊ុំ?

ខៈ ឈ្មោះពេញ ទឹម រុន។

កៈ ចាស! ចឹងអ៊ុំចាំទេ ថាអ៊ុំកើតនៅថ្ងៃទីខែឆ្នាំណាដែរ? ឬក៏ជំនាន់ណាដែរចឹងហ៎ា?

ខៈ កើតនៅឆ្នាំ៥៣(១៩៥៣)។

កៈ ១៩៥៣ អ៊ុំហ្ន៎?

ខៈ ចាស! ១៩៥៣។

កៈ អ៊ុំចាំទេថាអ៊ុំកើតនៅភូមិ ឃុំអីគេដែរ?

ខៈ នៅឯស្រុកកំពត ភូមិស្រែថ្នឹង។

កៈ ចាស!

ខៈ ស្រុកឈូក។

កៈ ខេត្តកំពតហ្នឹងអ៊ុំហ្ន៎?

ខៈ ចាស! ខេត្តកំពត។

កៈ ចាស! ហ្នឹងហើយ។ ចឹងសម្រាប់ជីវិតរបស់អ៊ុំវិញ តើអ៊ុំដូចជាកើតឆ្នាំខ្មែរហាដូចជាឆ្នាំខ្មែរយើងអ៊ុំកើតសត្វអីដែរ?

ខ៖ ឆ្នាំខ្មែរមិនចាំទេ។

ក៖ អាឆ្នាំជូត ឆ្លូវ ខាល ថោះ អ៊ុំអ៊ំកើតឆ្នាំអីគេ?

ខ៖ សត្វទន្សាយ!

ក៖ ទន្សាយចឹងឆ្នាំថោះ។

ខ៖ ចាស ឆ្នាំថោះ។

ក៖ អ៊ុំចាំថាកើតថ្ងៃទីប៉ុន្មានទេ?

ខ៖ អត់ចាំទេក្មួយ។

ក៖ ចឹងអត់អីទេ។ ចឹងតើឪពុកម្ដាយរបស់អ៊ុំគាត់ឈ្មោះអីគេដែរ?

ខ៖ ឪពុកម្ដាយឈ្មោះ ប៉ែន មុំ ឪពុកខ្ញុំឈ្មោះគឹម ផេង។

ក៖ ចាស! អ៊ុំចាំថាទាំង២នាក់នៅរស់ឬក៏គាត់ម៉េចហើយ ?

ខ៖ ស្លាប់ហើយអូន។

ក៖ ចាស! តើឪពុកអ៊ុំគាត់ស្លាប់នៅក្នុងជំនាន់ណាដែរ?

ខ៖ ហ៊ឺ! ឪពុកខ្ញុំស្លាប់តាំងពីនៃសង្គ្រាមឥស្សរណោះ។

ក៖ ចាស!

ខ៖ យន្តហោះទម្លាក់នោះ។

ក៖ ចាស! លន់ នល់ មែនអ៊ុំជំនាន់ហ្នឹង? មុនហ្នឹងមែន?

ខ៖ មុនហ្នឹង។ ម៉ែខ្ញុំស្លាប់នៅឆ្នាំ៧៩(១៩៧៩)នេះហ្នឹង។

ក៖ ពេលបែកនៅ?

ខ៖ បែកហើយអាហ្នឹងគេរត់ចូលព្រៃបែកហើយ។

កៈ ហើយបែក ហើយស្លាប់ក្នុងពេលជិតបែកហ្នឹង?

ខៈ ស្លាប់ពេលជិតបែកហ្នឹង ស្លាប់នៅក្នុងព្រៃ។

កៈ ចាស! ហ្នឹងហើយ។

ខៈ ស្លាប់បានមួយអាទិត្យ ញ៉ុមចេញមកព្រំដែន។

កៈ ព្រំដែនគេហៅឈ្មោះអីដែរព្រំដែនដែរអ៊ុំមក ?

ខៈ ព្រំដែនថៃ។

កៈ ហ្ហ៎! ដល់កន្លែងជិតបាត់ដំបង សំឡូតអត់ហ្នឹងម៉ងហោ៎?

ខៈ ទៅចេះវិញ ទៅថៃម៉ង ទៅចូលថៃម៉ងមកដល់។

កៈ ចាស! ហ្នឹងហើយ។ ហើយអ៊ុំ អ៊ុំចាំថាឪពុកម្ដាយរបស់អ៊ុំ ដូចជាឪពុកគាត់កើតឆ្នាំប៉ុន្មានអត់?

ខៈ ហ៊ឹ! ឪពុកខ្ញុំមិនដឹងឆ្នាំអីទេខ្ញុំឪពុកស្លាប់ ខ្ញុំទើបតែចេះអង្គុយ អត់ដឹងទេខ្ញុំហ្ហ៎។

កៈ អូ! ចាស! ចុះម្ដាយរបស់អ៊ុំវិញ?

ខៈ ម្ដាយខ្ញុំស្លាប់៦៦(១៩៦៦) ប៉ុន្ដែមិនដឹងគាត់កើតឆ្នាំអី?

កៈ គាត់ស្លាប់៦៦(១៩៦៦) ឬក៏៧៩(១៩៧៩)។

ខៈ អាយុគាត់៦៦។

កៈ ហ្ហ៎! ប៉ុន្ដែស្លាប់១៩៧៩?

ខៈ តែស្លាប់១៩៧៩។

កៈ ចាស! ចឹងសម្រាប់ឪពុកគាត់ស្លាប់នៅក្នុងពេលជំនាន់ឥស្សរ?

ខៈ ជំនាន់ឥស្សរ ហ៊ឹ! ជំនាន់ហ្នឹងដូចហាជាងហើយពុក។

កៈ ចាស! ហាជាងហើយ។

ខៈ ហាជាង។

កៈ ចឹងសម្រាប់អ៊ុំចាំឈ្មោះតាយាយទេ? ឥឡូវតាខាងឪពុកវិញ គាត់ឈ្មោះតាអីគេដែរ? យាយអីគេដែរ?

ខៈ តាខាងឪពុកមិនដឹងឈ្មោះអីទេ បើតា(ប្តី)ខ្ញុំបានស្គាល់។

កៈ ចាស! ចឹងខាងម្តាយបានស្គាល់ហ៎ៅ?

ខៈ ខាងម្តាយឈ្មោះ វ៉ុន តូច។

កៈ តារបស់ខាងម្តាយ?

ខៈ ចាស! ខាងម្តាយ។

កៈ ចុះយាយវិញឈ្មោះយាយអីគេដែរអ៊ុំ?

ខៈ ម៉ែខ្ញុំឈ្មោះ មុំ។

កៈ ចាស! ហ្នឹងហើយ។

ខៈ ឈ្មោះ វន មុំ។

កៈ ចឹងអ៊ុំតើសម្រាប់ពេលវេលាអ៊ុំជាមួយឪពុកម្តាយហ៎ា អ៊ុំមានការចងចាំអីគេខ្លះជាមួយគាត់ ដូចជាគាត់បានផ្តល់សុភមង្គលក្តីស្រឡាញ់ការអប់រំណែនាំម៉េចដែរអ៊ុំ?

ខៈ ឪពុកម្តាយណែនាំឱ្យកូនល្អខ្ញុំការតាំងពីអាយុ តាំងពីម្តាយខ្ញុំនៅរស់នោះ។

កៈ ពេលអ៊ុំការណោះ?

ខៈ ចាស! ប៉ុន្តែខ្ញុំការ៦៩(១៩៦៩)។

កៈ ចាស!

ខ៖ ការបានកូន១ បានចូលព្រៃមក។

ក៖ ចាស! ហ្នឹងហើយ ដូចជាអ៊ុំចងចាំអនុស្សាវរីយ៍ខ្លាំងជាងគេជាមួយគាត់?

ខ៖ ហ្អើ! កសិករអូនអើយ កសិករពេញទំហឹងហ្មងធ្វើស្រែ ធ្វើចម្ការម៉ងហ្នឹងហាំ។

ក៖ ចាស! អ្នកចម្ការ?

ខ៖ អ្នកចម្ការម៉ងហាំ។

ក៖ ចាស! ពេលធ្វើ ធ្វើនៅកំពតហ្នឹងម៉ងអ៊ុំណោះ?

ខ៖ ចាស! កំពតស្រុកកំពតហ្នឹង។

ក៖ ចម្ការអ៊ុំដាំតែស្រូវឬក៏មានដាំដំណាំអីផ្សេងទៀត?

ខ៖ ដាំ មានដាំស្វាយ មានដាំឪឡឹក ដាំចម្ការវាមានដាំដំណាំធំហ្នឹងហើយ អត់ដែលដាំពោតទេ ជំនាន់ហ្នឹង ដាំតែឪឡឹក ដាំតែត្រសក់អីហ្នឹង ហើយស្រែក៏យើងស្ទូងជាធម្មតា។

ក៖ ចាស! ហ្នឹងហើយ។ ចឹងសម្រាប់អ៊ុំទីលំនៅអ៊ុំបច្ចុប្បន្នកន្លែងហ្នឹងគេហៅភូមិឃុំអីគេដែរអ៊ុំ?

ខ៖ នេះហោ៎?

ក៖ ចាស!

ខ៖ នេះនៅណេ ភូមិព្រៃករំចេក ឃុំតាសាញ នេះ។

ក៖ ស្រុកខេត្តអីគេ?

ខ៖ ស្រុកសំឡូត ខេត្តបាត់ដំបង។

ក៖ ដូចថាអ៊ុំចេញមកពីសម័យប៉ុលពតដែលអ៊ុំមានគ្រួសារនៅជាមួយបងប្អូនពេលឪពុកម្ដាយខូចអស់ហើយ?

ខ៖ នៅជាមួយគ្រួសារអីនេ៎ នៅជាមួយបងប្អូនអី យើងមានគ្រួសារចឹងយើងនៅអង្គភាព។

កះ បានគ្នានៅអាពត?

ខះ ចាស! ហ្នឹងហើយតាំងពី៦៩(១៩៦៩)មក ខ្ញុំចេញមកឆ្នាំ៧០(១៩៧០)ហើយ។

កះ ចាស! ចឹងអ៊ុំសម្រាប់អ៊ុំមានអនុស្សាវរីយ៍អីថែមទៀតជាមួយម្ដាយ ឬ ក៏ឪពុកអីអត់ដែរអ៊ុំចង ចាំ?

ខះ ហ៊ឺ! ម្ដាយ ម្ដាយខ្ញុំគាត់នៅជាប់លាប់ជាមួយខ្ញុំរហូតរត់ តាំងពីណាពីណឹមកមកជួបគ្នានៅ ចុងបញ្ចប់ហ្នឹងក៏ស្លាប់នៅនឹងដៃខ្លួនឯងតែម្ដង។

កះ នៅហ្នឹងដែរអ៊ុំពេលគាត់ស្លាប់ហោ៎?

ខះ ចាស! ចាស! ហ្នឹងឯង។

កះ ចាស!

ខះ ពេលហ្នឹងអ៊ុំណោះសម្រាលកូនខ្ចីទៀតដល់ជិះដំរីមកវា ហើមជើង ប៉ុនៗណោក ទើបបាន ៣ថ្ងៃទេ។

កះ ចាស!

ខះ បាន៣ថ្ងៃ ជិះដំរីមកមើលគាត់ គាត់មកមុនផ្លាស់ ផ្លាស់កន្លែងណា។

កះ ហ្ហ៎!

ខះ ផ្លាស់កន្លែងក្នុងព្រៃ តែគាត់មកមុនហើយនេះប្រវត្តិគាត់ គាត់ត្រូវទឹកភ្លៀងហ្នឹង លាប់ទឹក ភ្លៀង។

កះ ហ្ហ!

ខះ លាប់ទឹកភ្លៀង។

កះ ចុះគាត់ស្លាប់ដោយសារគាត់ឆ្លងទន្លេឬក៏អ៊ុំអ្នកឆ្លងទន្លេពេលហ្នឹង?

ខះ ខ្ញុំឆ្លងទន្លេ!

កៈ ហ្ហ៎!

ខៈ តែម្ដាយហ្នឹងគាត់លាប់ទឹកភ្លៀង។

កៈ ហ្ហ៎ ចាញ់?

ខៈ ចាញ់ គ្រុនចាញ់ហើយលាប់ ដល់ពេលលាប់ហើយ ប្រញាប់គក់សារុងហើយពេលមេឃកំពុងតែភ្លៀងហ្នឹងហាំ។ បង្ហើយអាសារុងហ្នឹង ងូតទឹកហើយ ហ្អើយ ងូតឱ្យថៅគាត់ហើយអស់ហើយ តែគាត់បង្ហើយសារុងគាត់ហ្នឹង ក៏ត្រូវទឹកភ្លៀងមកដល់រឹងថ្កាមបណ្ដោយ ពេលហ្នឹងគាត់៦៦ម្ដាយខ្ញុំ ហ្នឹងហើយ។

កៈ ចាស! ចឹងអ៊ុំតើអ៊ុំមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ ស្រីមាន៣ ប្រុសមាន៧។

កៈ ចាស! ហើយពួកគាត់យ៉ាងម៉េចដែរឥឡូវ?

ខៈ ឥឡូវពួកគាត់ស្លាប់អស់ហើយនៅតែ។

កៈ ស្លាប់ពេលជំនាន់ណាដែរ? ជំនាន់យើងនេះហ្នឹង នែ៎លោកពតហ្នឹង។ លោកពត លោកប៉ុល ពត។

ខៈ ជំនាន់ហ្នឹងក៏គេអត់មានធ្វើទារុណកម្មអីយើងដែរណា។

កៈ ចាស!

ខៈ គាត់ស្លាប់ដោយសារជម្ងឺ ជម្ងឺគាត់ចឹងទៅ ដូចថាគាត់បារម្ភខ្លាំងនឹងប្រទេសជាតិ គាត់ដាច់សរសៃឈាម ខ្លះដាច់សរសៃរឈាមស្លាប់ទៅ ខ្លះក៏តាមជម្ងឺរបស់គាត់ ដូចជារបៀប...

កៈ គាត់ស្លុត ខ្លាំងពេកអ៊ុំណោះ?

ខៈ ចាស! ដូចថាពិបាក ពិបាកក្នុងការ ក្នុងអារម្មណ៍របស់គាត់ហាំ។

កៈ ចាស! ហើយអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំទីចុងបញ្ចប់ពៅគេ។

ក៖ ពៅគេ ដូចខ្ញុំដែរ។ ចាស! ចឹងអ៊ុំ អ៊ុំចាំឈ្មោះបងប្អូនរបស់អ៊ុំទាំងអស់ទេ ទាំងត្រកូលរបស់គាត់ពីអ៊ុំពៅគេ គាត់ឈ្មោះអីគេដែរ អ៊ុំអាចរៀបរាប់ប្រាប់ឈ្មោះ?

ខ៖ ត្រកូលរបស់បងប្រុស បងស្រីខ្ញុំទី១ ស្រី។

ក៖ គាត់ឈ្មោះអីគេដែរអ៊ុំ ?

ខ៖ គាត់ឈ្មោះ សន ។

ក៖ អីគេ សន?

ខ៖ ទេមិនដឹងគាត់ដាក់ជីតាខាងអីទេ ចែខ្ញុំ ប៉ុនខ្ញុំដាក់ទឹម។

ក៖ ចឹងទឹមសន ចឹងទៅហ៎ោ។

ខ៖ ចឹងហា។

ក៖ ចាស!

ខ៖ ដូចគ្នាទាំងអស់ហ្នឹង។

ក៖ ចាស! ចឹងទីមួយឈ្មោះ សន?

ខ៖ ចាស!

ក៖ ចុះដល់ពេលទី២?

ខ៖ ឈ្មោះ ចេង ទឹម ចេង។

ក៖ ចាស! ដល់ពេលទី៣?

ខ៖ ទី៣ ទឹម សេង។

ក៖ បន្ទាប់ទៀត?

ខ៖ ទី៤ ទឹម ស៊ឹម ទី៥ ទឹម ញៀវ ទី៦ ទឹម រ៉េន។

ក៖ មិញប៉ុន្មាននាក់អ៊ុំ ?

ខ៖ ៧នាក់។

ក៖ ចឹងដល់ពេលអ៊ុំ ទឹម រុន?

ខ៖ ចាស!

ក៖ ចាស! ចឹងអ៊ុំដូចជា...

ខ៖ ទឹម រុន! ទឹម រ៉ាន់ បងស្រីខ្ញុំមួយទៀត ទឹម រ៉ាន់ហើយបានទឹម រុន ទៀត។

ក៖ ចាស! ហើយអ៊ុំមានអនុស្សាវរីយ៍អីខ្លះជាមួយបងប្អូន អំឡុងពេលគាត់បានរស់នៅ ពេលពួកគាត់អត់ទាន់ស្លាប់ចឹងហា៎?

ខ៖ មានម៉េច មានអារម្មណ៍ហេ៎?

ក៖ ហ្នឹងហើយដូចធ្លាប់មានលេងមានស្អីគេខ្លះជាមួយគាត់ស្អីនិយាយគ្នាចឹងទៅណា?

ខ៖ ហ្អ! និយាយទៅបងប្អូនខ្ញុំ រួមរស់ជាមួយគ្នា ដូចថាមិនបានបិតថេរអី សប្បាយអីក្នុងការលេងសើចទេ។

ក៖ ចាស!

ខ៖ បងប្អូនអត់ដឹងចិត្តគ្នាទេ តែស្រឡាញ់ៗហើយគ្នា តែបងស្រីរបស់ខ្ញុំ២នាក់ ហ្នឹងចូលចិត្តលេងជាមួយប្អូន តែធម្មតាបងប្រុសមិនដូចយើងបងស្រីទេ។

ក៖ ចាស! ពេលជំនាន់អ៊ុំ ជំនាន់ប៉ុលពត អ៊ុំអាយុប៉ុន្មានវិញ?

ខ៖ ហេ៎! កាលហ្នឹងខ្ញុំទើបតែកូន១ កាលហ្នឹង។

ក៖ ចាស!

ខ៖ ប៉ុល ពត ហ្នឹងទើបនឹងបានកូន ស្រី១ បងគេហ្នឹង។

ក៖ ចាស! ហ្នឹងហើយ។

ខ៖ ប៉ុន្មានទេពេលហ្នឹង អាចសែជាងអីហ្នឹង កាលចេញមក អាយុម្ភៃជាងហ្នឹង ចេញមកហើយដល់ខ្ញុំមកមែនតិចឆ្នាំណា ចង់៩០ឆ្នាំឥឡូវហើយហ្នឹង។

ក៖ ចាស! ចុះអ៊ុំសព្វថ្ងៃអាយុប៉ន្មានហើយ?

ខ៖ ឥឡូវ៦៧ហើយ។

ក៖ ចឹងមានន័យថាពេលហ្នឹងអ៊ុំអាយុ២៧?

ខ៖ ចាស! ប៉ុណ្ណឹងគិតទៅឃើញហា៎ ចេញតាំងពីអាយុ៧០មកហា ឆ្នាំ៧០(១៩៧០)មក។

ក៖ ចាស! ហ្នឹងហើយ។ ចឹងអ៊ុំខ្ញុំចង់សួរពីជីវិតអ៊ុំមួយដំណាក់កាលម្ដងៗចឹងហា ចង់អ៊ំកើតទាន់ជំនាន់លន់នល់មែនទេអ៊ុំ? ពេលហ្នឹងអ៊ុំក៏កើតទាន់ជំនាន់ពេលសម្ដេចសីហនុ គាត់គ្រងរាជដែរមែនទេអ៊ុំ?

ខ៖ ទាន់ៗតើ!

ក៖ ចឹងអ៊ុំមានចាំអីគេខ្លះនៅក្នុងពេលដែលអ៊ុំរស់នៅក្នុងជំនាន់សម្ដេចសីហនុ អ៊ុំជួបហ្នឹងរឿងអីគេខ្លះដែរពេលជំនាន់ហ្នឹង?

ខ៖ ហ៊ឺ! កាលហ្នឹងអ៊ុំនៅជាមួយបន្ទុកម៉ែកាលហ្នឹងនោះឪពុកម្ដាយហា៎។

ក៖ ចាស! ដូចថាមានអារម្មណ៍អីដូចថាគាត់សម្គាល់ក្នុងចិត្តផង។ ចាស!

ខ៖ ប៉ុន្មានតែសប្បាយក្នុងជំនាន់ខ្ញុំហ្នឹងហ្ន៎។

ក៖ តែពេលហ្នឹងការដឹកនាំរបស់ស្ដេចល្អណាស់មែនហេ៎អ៊ុំ?

ខ៖ ចាស!

ក៖ គាត់ស្រឡាញ់រាស្ត្រ។

ខ៖ ចាស! ស្រឡាញ់រាស្ត្រខ្លាំងណាស់។

ក៖ ចាស!

ខ៖ មានអីក៏ដល់រាស្ត្រដែរ។

ក៖ ចាស! ហ្នឹងហើយ។ ចឹងហើយដល់ឆ្លងផុតដល់ពេលជំនាន់សម្តេចមក ចូលដល់របបលន់នល់មែនទេអ៊ុំអី?

ខ៖ ចាស! ចូលរបបលន់នល់។

ក៖ ចឹងអ៊ុំអាចរៀបរាប់ពីអ្វីដែលអ៊ុំចាំហា៎?

ខ៖ ជំនាន់លន់នល់ ហ្នឹងក៏អត់ចាំ អត់បានសូវចាំប៉ុន្មានទេកូន។ បើនិយាយទៅគ្រួសារខ្ញុំចាំច្រើន ចាំច្រើនជាងខ្ញុំ ព្រោះខ្ញុំ៧៩(១៩៧៩) សន្លប់ដឹងប៉ុន្មានដងហើយ វាដូចថាងាប់២ឬ ក៏៣សារហើយកូន ងាប់ហ្នឹង ងាប់២ឬ៣ដងហើយ។

ក៖ ចាស!

ខ៖ គេសែងរករហូតហ្នឹង អាហ្នឹងដោយសារយើងមានខ្សែហាបានគេសែង។ បើអត់ខ្សែអាហ្នឹង គេចាប់ដាក់ចោលនៅក្នុងព្រៃហើយ។

ក៖ ខ្សែរបៀបម៉េចទៅអ៊ុំ ដូចថាមានខ្សែបងប្អូនយើងធ្វើការអីចឹងទៅណា។ ចាស!

ខ៖ អើ! ចំណែកអាម្ហូបអាហារអីគឺមានគេជួយជ្រំជ្រែងយើងទៅណា បើនៅតែធម្មតាដូចប្រជាជនសាមញ្ញស្លាប់អស់ហើយ ខ្ញុំស្លាប់។

ក៖ ចាស! ចឹងជីវិតរបស់អ៊ុំឆ្លងកាត់របៀបផ្អែកផ្សេងចឹងទៅ។

ខ៖ ចាស! អូនឆ្លើយផ្សេងទៅ។

ក៖ ចាស! ចុះអ៊ុំពេលងាកមកពេលមករបបជំនាន់លន់នល់វិញ ដូចពេលហ្នឹងអ៊ុំដូចឃើញមានគេទម្លាក់គ្រាប់បែកឬក៏ឃើញអីទេ?

ខ៖ អ្ហើយ! និយាយធ្វើអីកូនអើយទាំងខ្សែ។

ក៖ អ៊ុំអាចរៀបរាប់ពីអ្វីដែលអ៊ុំបានចាំនៅក្នុងចិត្តរបស់អ៊ុំអំពីទិដ្ឋភាពទាំងអស់ហ្នឹងបានទេ?

ខ៖ កាលជំនាន់ហ្នឹងហ្ន៎និយាយពីគ្រាប់ គ្រាប់រាប់ខ្សែហ្នូរាប់មិនអស់ទេ។
អាហ្នឹងកំណើតកូនខ្ញុំមីបងបង្អស់ហើយហ្នឹង។

ក៖ ចាស!

ខ៖ កើតបាន៣ថ្ងៃទៅនៅក្នុងត្រង់សេកណ្ដាលវាលស្រែហ្នូ អត់បានឆ្អើរភ្លើង ឆ្អើរអីទេ។ ពេលអត់យន្តហោះទម្លាក់ទៅយើងដុតធែងដូងឆ្អើរទៅ ឆ្អើរកម្ដៅកូនទៅដល់ពេលយន្តហោះមកហ្វនាំគ្នាពន្លត់ភ្លើង ខ្លាចយន្តហោះឃើញ ហើយយាយៗ តែខ្ញុំនៅកន្លែងណាយាយៗ ទៅកន្លែងហ្នឹងហើយ ដឹងគាត់មានមនោសញ្ចេតនាលើយើង។ អ្ហើយ! ថៅហើយថៅពិបាកម្ល៉េះបាន៣ថ្ងៃមកអត់មានភ្លើងមានអីនាំគ្នាដុតភ្លើងឲ្យ។

ក៖ ចាស!

ខ៖ យាយៗ៦ និង៧ នាក់ហ្នឹងទៅនៅអេបតាហ្នឹង ហើយកូនខ្ញុំមីបងឆ្លោសនោះគេស្រឡាញ់។

ក៖ ចាស!

ខ៖ ដល់ចឹងទៅណា នៅហ្នឹងម៉ែខ្ញុំចាស់ៗនោះច្រើនណាស់។

ក៖ ចាស!

ខ៖ ទៅណាគេនៅជុំគាត់ហ្នឹងឯង។

ក៖ ចាស! ចឹងអ៊ុំដូចជាពេលទម្លាក់គ្រាប់ហ្នឹង បើទាហ៊ានហ្នឹងគាត់ឃើញមនុស្សនៅនេះគេទម្លាក់សម្លាប់ម៉ងហ៎?

ខ៖ និយាយទៅវាទម្លាក់ព្រៀវ បើសិនជាមិនទម្លាក់ព្រៀវ។ វាងាប់អស់ហើយអូន ម្ដង១២០គ្រាប់វ៉ាន់នោះ ទម្លាក់មួយជ្រឹបចឹងហា ទម្លាក់មួយព្រូចឹងទៅ១២០គ្រាប់។

កៈ ដាច់ខ្យល់បណ្ដោយ។

ខៈ ហើយរណ្ដៅប៉ុនៗត្រពាំងយើងហ៎ា រណ្ដៅហ៎ា។ បើទម្លាក់ចំត្រង់សេក៏អត់នៅដែរ។

កៈ ចាស! ចឹងអ៊ុំរបៀបដែលគេធ្វើត្រង់សេគេធ្វើម៉េចដែរ ដោយសារពួកខ្ញុំដូចជាក្មេងចឹងហ៎ា។ ពួកខ្ញុំអត់ដឹងថាអីគេជាត្រង់សេទេ គ្រាន់តែដឹងថាជារណ្ដៅមួយ ដូចថាវាមានលក្ខណាម៉េចទៅអ៊ុំ?

ខៈ រណ្ដៅត្រង់សេចឹង ជួនអីមានដំបូកធំចឹង ខូងកណ្ដាលដំបូកធ្វើហ្ហ ខូងធំហ៎ាណ៎ា ចូលទៅក្នុងទៅណា អាហ្នឹងមួយបែបមួយបែបទៀតគេច្រស់ឈើអញ្ចេក។

កៈ ចាស!

ខៈ ប្រហោងចឹងហ៎ោ។

កៈ ចាស!

ខៈ ហើយគេដាក់ដីពីលើអាឈើចឹងមកអាហ្នឹងទម្លាក់ក៏អត់ប៉ះពាល់មនុស្សដែរ។

កៈ ហ្ហ៎!

ខៈ គេធ្វើច្រោះចឹងហ៎ោ។

កៈ ហ្នឹងហើយ។

ខៈ ហើយមានរន្ធខាងណោះ មានរន្ធខាងណោះ។

កៈ ទុកឲ្យខ្យល់ចេញចូល។

ខៈ ទុកឲ្យដង្ហើមចេញចូលហើយ សម្រាប់យើងរត់ចេញ។

កៈ ហ្ហ!

ខៈ ពិបាកណាស់អូនអើយ។

កៈ រស់ដោយការភ័យខ្លាចរហូតមែន។

ខៈ រស់រហូត រស់នេះមិនមែនរស់ដោយស្រួលទេ រស់ដោយការលំបាក រត់រហូតជូរចត់ណាស់ ហើយបាយអត់ដែលបានហូបលើទេ។ ហូបតែក្នុងត្រង់សេទៀតពេលវាទម្លាក់មក គ្រាន់តែឮ ងឹងហ្នឹង គ្រុងមកដល់ហើយ គ្រាប់ធ្លាក់បាត់ហើយ អាហ្នឹងសុទ្ធតែអាកាច្រើប អាយន្តហោះកាច្រើបៗស្លាបវានោះហាំ ដឹកគ្រាប់ម្តងៗ២ខ្សែ ៣ខ្សែហ្នុំ។

កៈ ចាស! អ៊ុំចាំទេដំបូងឡើយបានជាវាទម្លាក់គ្រាប់ចឹងហាំ? ចាំទេពេលដំបូង?

ខៈ ទេ! ឆ្ងល់ដែរ។

កៈ ថ្ងៃដំបូងឮមកទម្លាក់ជឹងចឹងម៉ង។

ខៈ ស្រាប់តែទម្លាក់ ដំបូងទម្លាក់គៀតភ្នំ គៀតភ្នំយើងចេះតែចាប់អារម្មណ៍ យើងធ្វើត្រង់សេទៅ។

កៈ ចាស!

ខៈ ហ៊ី! គេមានអ្នកដឹកនាំអ្នកដឹកនាំដូចតែគ្នាណាអូន។

កៈ ចាស!

ខៈ អ្នកដឹកនាំ គេប្រកាសថាត្រូវជីកត្រង់សេ ថាត្រូវទៅពួនក្នុងព្រៃកុំនៅក្នុងភូមិចឹងទៅណា។ គេដឹកនាំយើងចឹង យើងធ្វើតាមគេមានមេគេហាំ។

កៈ ចឹងមានអ្នកប្រាប់យើងមុនចឹងទៅអ៊ុំណោះ?

ខៈ មានៗអត់ៗទេ។

កៈ ដល់ពេលស្តាប់ជំនាន់ចឹងទៅដូចមានអារម្មណ៍ថាបើនៅក្នុងជំនាន់ក្នុងស្ថានភាពមួយហ្នឹងហាដឹងមានអារម្មណ៍ពិបាកប៉ុណ្ណាទេអ៊ុំហ្នូ?

ខ៖ និយាយទៅវាពិបាកណាស់អូនអើយ នែ៎! អារម្មណ៍ដូចថាមិននៅក្នុងខ្លួនផង។ បើអារម្មណ៍ដូចថាព្រួយបារម្ភ ព្រួយគិតដាំបាយហូបដាក់កូននៅត្រង់សេហ្នឹងទៅ។

ក៖ ចាស!

ខ៖ អារម្មណ៍លំបាកនោះ ដាក់គ្រាំចឹងទៅ ក្របីគោ ងាប់រលៃចឹងទៅ។

ក៖ ហើយដល់ពេលក្របីគោងាប់ចឹង មនុស្សមានទៅយកក្របីគោហ្នឹងយកមកហូបទេ?

ខ៖ ដល់ពេលដែលស្ងាត់ហ្នឹងហូបទៅ ហ្ន៎! អាហ្នឹងវាមានទម្លាក់មួយថ្ងៃ២ដង។ វាទម្លាក់តែម្តងទេ ម៉ោង៣រៀបភ្លឺហ្នឹងវាដាក់ហាំ។

ក៖ ហ្ន៎! ចឹងទៀត។

ខ៖ មួយថ្ងៃទម្លាក់មួយម្តង។

ក៖ មួយថ្ងៃទម្លាក់មួយម្តង។ កំណត់ចឹងម៉ង?

ខ៖ អើ! អាខ្សែហ្នឹងវាទម្លាក់តែម្តងទេ ហើយបើអាអត់ខ្សែស្លាបកាត់អីហ្នឹង អាហ្នឹងព្រឹកល្ងាចម៉ោង៨ឬ៩ដល់ហាំ ហើយដល់ម៉ោង៣ឬ៤អីដល់ទៀតហាំ។

ក៖ គេទៀងឱ្យដែរហ្ន៎?

ខ៖ ហ្នឹងឯង។

ក៖ ទម្លាក់ហ្នឹងខាងណាវិញ?

ខ៖ អត់ដឹងទេ អត់ដឹង។

ក៖ លាយឡំគ្នា។

ខ៖ មិនដឹងថាពួក លន់ នល់ឬក៏ពួកខាងណាមកវិញ។

ក៖ មិនដឹងថាមួយណាប្រជាជនមួយណាខ្មាំង វាទម្លាក់ងាប់អ្នកណាក៏បាន។

ខ៖ ហ្នឹងហើយ។ ប៉ះណាងាប់ហ្នឹងទៅ។

ក៖ ហើយអ៊ុំដឹងថាគោលបំណងរបស់គេដែលទម្លាក់គ្រាប់ហ្នឹងអីគេអត់?

ខ៖ វាមិនដឹងអាគោលបំណងគេវាចង់បានអីលើយើងហ្នឹង វាពិបាកទៀតហ៎។ វាចង់បានប្រទេស យើងឬវាចង់បានឬវាចង់បានទឹកដីយើងហ៎ វាមិនដឹងដែរ។

ក៖ ចាស! ហ្នឹងហើយ។

ខ៖ យើងចេះតែរត់ ចេះតែពួនទៅ។

ក៖ ចាស! ចឹងអ៊ុំមានអ្នកដែលស្គាល់ក្នុងពេលរបប លន់ នល់ហ្នឹងអ៊ុំមានស្គាល់នរណាគេដែលគាត់ស្លាប់នៅក្នុងរបបហ្នឹងអត់? ដូចគាត់បានស្លាប់នៅក្នុងជំនាន់ហ្នឹងគេទម្លាក់គ្រាប់នៅក្នុងជំ-នាន់ហ្នឹងត្រូវចឹងហ៎? មានស្គាល់ដែរអ៊ុំហ៎ មានបងប្អូនសាច់ញាតិស្លាប់នៅក្នុងជំនាន់ហ្នឹងទេ?

ខ៖ ជំនាន់សេរីហ្នឹងដូចដែរចាស់ៗចឹងទៅ ខ្ញុំដូចនៅស្ទើរដែរហ្នឹងណាជំនាន់ហ្នឹងហ៎។

ក៖ ចាស!

ខ៖ ដូចថាចាំវាមិនបានដូចថាមុនចឹង ខ្ញុំចាំមិនអស់ទេ ព្រោះខ្ញុំវាឆ្លងកាត់ជម្ងឺវាច្រើនពេកហើយ។

ក៖ ចាស!

ខ៖ ចាំអត់អស់ សួរខាងប្ដីខ្ញុំនោះដឹងហើយ។

ក៖ ចាស! អូខេឥឡូវអរគុណមែនទែនដែលបានប្រាប់ពីមួយហ្នឹង។ ឥឡូវចប់របបលន់នល់ហើយ ចូលដល់របបជំនាន់ប៉ុលពតម្ដងដោយសារពេលចប់ លន់នល់ ហ្នឹងភ្លាមចូលដល់ ប៉ុលពតម្ដងវិញមែនអ៊ុំ?

ខ៖ ហ៊ឺ!

ក៖ អ៊ុំចាំថ្ងៃដំបូងដែលចេញពីរបបលន់នល់ ចូលក្នុងរបបប៉ុលពត។ វាមករបៀបម៉េចដែរ ប៉ុលពតហ្នឹង មានការដេញប្រជាជនឬក៏ម៉េចដែរអ៊ុំ?

ខ៖ ទេធម្មតាចូលដំបូងអត់មានដេញអត់មានអីទេអីទេមីអូននិយាយត្រង់ម៉ងហា៎។

ក៖ ចាស!

ខ៖ គឺគេមកស្រួល គេមកសុំបាយសុំអង្ករយើងហូបស្រួលតើ តែដោយឡែកដូចថា យើងដូចថាខ្មែរក្រហមចូលបានដូច១ម៉ោង កន្លះម៉ោង ដូចឆក់កន្ទៀតហ្នឹងទៅណា អាហ្នឹងនៅលាយឡំជាមួយពួកលន់នល់ដែរ ដល់គេចេញផុតលន់នល់នៅមកដឹកនាំយើងដដែល។

ក៖ ចាស!

ខ៖ ចឹងពាក្យថាខ្មែរក្រហមរបៀបលួចលាក់ហា៎។

ក៖ ចាស! ហើយចុះម៉េចដូចជាខ្មែរក្រហមចូលមកពេញសិទ្ធកាន់កាប់ហើយធ្វើបាបប្រជាជនទៅអ៊ុំ?

ខ៖ ខ្មែរក្រហមវាចូលតាំងពីឆ្នាំ៧០ (១៩៧០) ហោ៎។

ក៖ ៧៥(១៩៧៥)។

ខ៖ ៧៥(១៩៧៥) រំដោះភ្នំពេញ។

ក៖ ៧៩(១៩៧៩) បានរំដោះហី?

ខ៖ ហ្ហឺ! ៧៥(១៩៧៥)ហា៎។

ក៖ ដោយសារជំនាន់ប៉ុលពត៧៥ដល់៧៩(១៩៧៥ដល់១៩៧៩)ហ្ហ៎អ៊ុំ?

ខ៖ អឺៗ!

ក៖ តែដល់ពេលអា៧០ដល់៧៥ហ្នឹង(១៩៧០ដល់១៩៧៥)ជំនាន់ លន់ នល់។

ខ៖ អើៗៗ!

កៈ ចឹងដូចថាអ៊ុំរៀបរាប់ពីជីវិតអ៊ុំបានកើតឡើងអីគេខ្លះ បទពិសោធន៍អ៊ុំក្នុងជំនាន់ប៉ុលពត ហ្នឹង អ៊ុំឆ្លងកាត់អីគេខ្លះហា៎?

ខៈ ហ្វ! និយាយពីឆ្លងកាត់ហ្នឹងនិយាយពីឆ្អែតឆ្អល់ហើយអូនហា៎ ផ្លាស់បើអង្គភាពមួយទៅអង្គ ភាពមួយ។ អ៊ុំនៅអង្គភាពគ្រប់កន្លែងម៉ងហា៎ ផ្លាស់ពីអង្គភាពមួយចូលអង្គភាពមួយស្រេចតែ គេ ទាញទៅដាក់កន្លែងណាលំបាកដាក់កន្លែងហ្នឹងហើយ។

កៈ ចាស!

ខៈ កន្លែងពេទ្យចឹងមួយ ថ្ងៃស្លាប់១៥នាក់ចឹងយកអ៊ុំយកអ៊ុំទៅដាក់កន្លែងហ្នឹង ព្រោះកន្លែង ពេទ្យហ្នឹងមានអ្នកក្បត់ចាក់ ថ្នាំសម្លាប់ សម្លាប់ពួក១៧មេសាហ្នឹងហា៎ រំដោះចេញមកតាមភូមិ ហ្នឹងដល់ពេលខ្ញុំចូលទៅអត់មានស្លាប់អីមួយទេ។ វាបើកថ្នាំមកវាអត់ចាក់ឲ្យប្រជាជនទេ។

កៈ ចាស!

ខៈ ចឹងខ្ញុំទៅកន្លែងពេទ្យហ្នឹងខ្ញុំព្យាបាលអត់មានឲ្យស្លាប់អីមួយទេ។

កៈ ចឹងពេលហ្នឹងអ៊ុំជាពេទ្យហោ៎?

ខៈ ពេទ្យពេលហ្នឹង។

កៈ ចឹចឹងបានអ៊ុំរាងស្រួលជាងគេមែនទេអ៊ុំ?

ខៈ ហ្នឹងហើយ ធ្វើពេទ្យពេលហ្នឹងគឺពេទ្យពេលហ្នឹងអត់មានចេះអីទេ។

កៈ ម៉េចចឹងវិញ?

ខៈ អត់មានចេះអីសោះ គេអោយទៅដឹកនាំពេទ្យហ្នឹង។

កៈ ហ៊ឺ!

ខ៖ ដ៏ទៅយើងព្យាបាលតាមដំណើររបស់យើងត្រូវដែរ ដូចយើងដឹងយើងចេះតែម្តងហា៎ ដូចថាចេះចឹងអ៊ុំធ្វើពេទ្យហ្នឹងបានប៉ុន្មានឆ្នាំទេ។ ចេញពីពេទ្យហ្នឹងមកគេយកទៅដាក់កន្លែងកាត់ដេរទៀត។

ក៖ ចាស!

ខ៖ ឆ្លងកាត់ច្រើនកន្លែងណាស់អ៊ុំ។

ក៖ ចាស! ហ្នឹងហើយ។ ចឹងពេលនៅក្នុងពេទ្យហ្នឹងគេមានបញ្ហាអីពីក្នុងមកអត់ថាឱ្យអ៊ុំត្រូវធ្វើម៉េចៗហា៎?

ខ៖ ហ្ហ៎! រឿងពេទ្យបញ្ហាអីបើយើងប្រធានគេហើយ អាណាបញ្ហាយើង។

ក៖ ចឹងស្រួលហើយ។

ខ៖ មានតែយើងបញ្ហាគេ។ ចាស!

ក៖ តែដល់ពេលមុនថាប្រើថ្នាំអីគេបានចាក់សម្លាប់មនុស្សដល់១៥នាក់ហ្ហ៎?

ខ៖ អាហ្នឹងពេលពេទ្យហ្នឹងវាក្បត់ ពេលក្បត់ពេលយើងចូលទៅភ្លាមចឹងទៅបានមួយអាទិត្យពីរអាទិត្យចឹងទៅ យើងទាញម្នាក់ហ្នឹងចេញទៅ យើងចូលមកនៅកន្លែងហ្នឹង។

ក៖ ចាស!

ខ៖ ម្នាក់ហ្នឹងចូលគុកទៅ។

ក៖ អូ! ចឹងអ៊ំដូចជាចិត្តពួកគាត់ម៉េចដែរបានជាហ៊ានសម្លាប់មនុស្សចឹងហា៎?

ខ៖ ពួកហ្នឹងខាងដូចថា ខ្មែរគេយួនហា៎។

ក៖ អ៊ូ!

ខ៖ ខ្មែរគេយួន ឈ្មោះថនថន ហ្នឹងយួន ចឹងទម្រាំតែដកវាចេញយូរថ្ងៃហា៎។

កៈ ចាស!

ខៈ ទម្រាំធ្វើនយោបាយដកវាចេញទៅយូរថ្ងៃហាំ វារឹងហាំស្រីប៉ុនរឹងណាស់ ដកចេញទៅយកទៅអើយើងរកវិធីដែរ នយោបាយវាទម្រាំវាទៅជាមួយយើង។

កៈ ហ្នឹងហើយ។ ចឹងបន្ទាប់ពីរពេទ្យមកអ៊ុំទៅធ្វើអីទៀតវិញ?

ខៈ ទៅកាត់ដេរ កន្លែងកាត់ដេរវិញ។

កៈ គេឱ្យកាត់ដេរខោអាវខ្មៅៗហ្នឹងហេ៎?

ខៈ ចាស! ចូលកន្លែងហ្នឹង។

កៈ ហើយដល់ចេញពីកាត់ដេរហ្នឹងធ្វើអីគេទៀតទៅអ៊ុំ?

ខៈ ទៅកន្លែងកងចល័តទៀតហាំ។

កៈ កាប់ដីអីអត់?

ខៈ អត់ទេ។

កៈ ធ្វើម៉េចកងចល័តហ្នឹងអ៊ុំអាចរៀបរាប់ប្រាប់តិចមើល?

ខៈ កងចល័តហ្នឹងមានអីយើងដឹកនាំ គេឱ្យធ្វើដូចថាកាលសេរីខ្មែរក្រហមហ្នឹងហូបបបរហ្នឹងហាកូនណាំ។

កៈ ចាស!

ខៈ ហូបបបរ ប៉ុន្តែអង្គភាពអ៊ុំអត់មានបបរនេះទេ ហូបបបរគោកតែម្ហូបអីសុទ្ធតែខត្រី អង្គភាពហ្នឹងអត់ដែលអត់បាយទេ តែហូបបបរ បបរគោក។

កៈ ចាស! អ៊ុំអ្នកដឹកនាំអ៊ុំណេ៎?

ខៈ ចាស! ហ្នឹងហើយ។

កៈ ចឹងអ៊ុំមានមេត្តាច្រើនពេលហ្នឹង។

ខៈ ហើយដល់អង្គភាពផ្សេង បបរដាក់បន្លែហើយ តែអង្គភាពឯអ៊ុំអត់ទេ។

កៈ ចាស! ដល់ពេលយើងធ្វើចឹងអាអ្នកធំៗលើអត់មានថាអីដែរ?

ខៈ អត់ទេអត់មានថាអីទេ។

កៈ ចាស!

ខៈ បើយើង និយាយទៅអ៊ុំវាមានខ្សែរបស់អ៊ុំហ៎ា។

កៈ ចាស!

ខៈ ដូចថាខ្សែរយៈស្រេចតែលើកទៅដាក់អង្គភាពណារាងតឹងតែង គេយកឯងទៅ ដាក់ហ្នឹងហា។

កៈ ចាស!

ខៈ ដាក់ហ្នឹង យើងដឹកនាំល្អ ល្អហ៎ាមនុស្ស។

កៈ ចាស! ហ្នឹងហើយ។ ហើយមួយៗគេស្រឡាញ់អ៊ុំខ្លាំងណាស់មែនទេ?

ខៈ ហួយយំស្រែក។

កៈ ចាស!

ខៈ ចេញ៧៩(១៩៧៩) យំស្រែកយំនោះយំ យំម្នាក់ៗខ្ញុំចេញអត់ចង់រួចទេណានៅប្រហែលតែ ៥០ម៉ែត្រ យួនចូលដល់កន្លែងហ៎ា ប្ដីខ្ញុំទៅយកហ្នឹងឮកាំភ្លើងហើយហ្នឹងឡើងទៅយកមិនបាន ១៥នាទីផង ចេញផុតយួនចូល។

កៈ ហើយយួនចូលមកធ្វើអីដែរអ៊ុំដឹងទេ?

ខៈ អាយួនចូលមក អង្គភាពខ្ញុំហ្នឹងរាងៗដឹងទៅណាអស់ទៅ។ បើខ្ញុំមេចេញបាត់ហើយនៅ តែកូនបែបតាមយួនអស់ទៅ។

កៈ ហ្នំ! តែពេលហ្នឹងជនជាតិហ្នឹងគេមកជួយយើងឬក៏ម៉េចដែរអ៊ុំ?

ខៈ ជនជាតិណា?

កៈ ពេលវៀតណាមចូលមកចឹងហា៎?

ខៈ វាដូចថាចូលមកដល់ខ្មែរក្រហមទៅយកវិញអាដែលយកវិញអាដែលកន្លែងហ្នឹងហា៎។

កៈ ចាស!

ខៈ ព្រោះកន្លែងហ្នឹងមានឃ្លាំងអង្ករ ឃ្លាំងក្រណាត់ចឹងទៅវាយយកកន្លែងហ្នឹងកន្លែងស្បៀង។

កៈ ចាស! ហ្នឹងហើយ។ ចឹងអ៊ុំសម្រាប់នេះវិញ ដូចជាការរស់នៅរស់នៅរបស់អ៊ុំដូចស្រួលដែរ តើដូចជាអត់សូវពិបាកប៉ុន្មានដែរ?

ខៈ អ៊ុំនិយាយទៅអត់ដែលហូបបបរដាក់បន្លែទេអត់ទេ។

កៈ អត់សោះម៉ង សំណាងហើយចឹង។

ខៈ បបរសដែរតែបបរគោក ហូបខត្រី ហូបខគោក។

កៈ អ៊ុំនៅភូមិ ឃុំអីគេដែរនៅជំនាន់ហ្នឹងចាំទេអ៊ុំ?

ខៈ នៅជំនាន់ហ្នឹងអង្គភាពកងនារីហ្នឹងហេ៎?

កៈ ចាស!

ខៈ នៅអង្គរបុរី។

កៈ នៅបន្ទាយមានជ័យមែនទេអ៊ុំ?

ខៈ អង្គរបុរីនៅឯកំពង់អំពិល កំពង់យោលហ្នំ។

កៈ ខេត្តអីគេវិញអ៊ុំ?

ខៈ ខេត្តតាកែវ។

កៈ ហ្នំជិតកំពតដែរចឹងហ្ន៎?

ខៈ ជិតខេត្តតាកែវ។

កៈ ចាស! ចឹងអ៊ុំដូចធ្លាប់ឃើញគេសម្លាប់នៅហ្នឹងក្អែកអីអត់?

ខៈ ហ៎ោ! អាដែងសម្លាប់ហ្នឹងខ្ញុំអត់ដែលឃើញទេ។

កៈ ចាស!

ខៈ និយាយាទៅអត់ដែលឃើញទេ។ សេរីហ្នឹងខ្ញុំទាន់ដំបូង៧៥(១៩៧៥)គេយកខ្ញុំទៅហ្នឹង អង្គភាពគេយកទៅហ្នឹងគេទៅហ្នឹង ដែលឃើញគេវះពោះមួយវះមនុស្សពោះធំវះមនុស្សហ្នឹងយួនទេណា៎។

កៈ ចាស!

ខៈ គេវះពិសោធន៍ ពេទ្យគេហា៎។

កៈ ចាស!

ខៈ គេវះពិសោធន៍តើបានប៉ុន្មានម៉ោង គេវះពិសោធន៍ហា ដែលពេទ្យយើងហ្នឹង ពេទ្យខ្មែរក្រហមវះពិសោធន៍ហា៎ វះយួនហា៎ យួនវះពិតៗម៉ង អ៊ុំថ្ងៃហ្នឹងអ៊ុំធ្វើចុងភៅគេទេ ចូលដំបូងចុងភៅមេៗគេ។

កៈ ចាស!

ខៈ ដល់ពេលព្រឹកឡើងម៉ោង៧ហ្នឹង ដើរតាំងតាំងទៅរកអំពិល បេះអំពិលខ្ចីហ្នឹងយកមកស្លហា។

កៈ ចាស!

ខៈ ដើរកាត់ក្រោមផ្ទះហ្នឹងសុទ្ធឈាម រត់មកវិញ រត់មកវិញមកសួរមេគេហ្នឹង។ ហ៊ី! កន្លែងហ្នឹងគេធ្វើអីគេ បានសុទ្ធឈាមដាបពេញក្រោម ផ្ទះចឹងខ្ញុំឆ្ងល់ព្រោះយើងអត់ដឹងហ្នំ។

ក៖ ចាស!

ខ៖ គេថាហេ៎កុំចេះដឹងរឿងរបស់គេ ចង់ដឹងម្លោះមិត្តរុនឯងឡើងលើផ្ទះវិញហ្ន៎ កុំទៅហ្នឹងប្រយត្ន័ខ្មោចលង។

ក៖ ស្លាប់បាត់ហើយហ្នឹងពេលហ្នឹងអ៊ុំណ្ហោះ?

ខ៖ ពេលហ្នឹងវះហើយអត់ស្លាប់ទេ។

ក៖ ពេលគេស្លាប់ចឹងម៉េចទៅអ៊ុំណ្ហោះ?

ខ៖ ឈាមអាលាក់ពេញក្រោមផ្ទះហ្នឹង។

ក៖ វះនៅឬក៏ម៉េចអ៊ុំដឹងទេ?

ខ៖ វះនៅៗ។

ក៖ ហើយចាប់ចងអីចឹងទៅ?

ខ៖ ដឹងម៉េចទេអូនហា អត់បានមើលលើផង ឃើញតែឈាមក្រោមផ្ទះ តែគេមែនវះនៅទេ គេអាចដាក់ថ្នាំសណ្ដំថ្នាំអីចឹងហ៎។

ក៖ ចាស! ហ្នឹងហើយ។ ពេលហ្នឹងចូលដល់ជំនាន់ហ្នឹងហើយណោះ?

ខ៖ ជំនាន់ខ្មែរក្រហមហា គេវះពិសោធន៍ហ៎។

ក៖ ចាស! ហ្នឹងហើយ។ ចឹងអ៊ុំសម្រាប់ពេលបងប្អូនរបស់អ៊ុំវិញម៉េចដែរ ដូចជាអ៊ុំអាចរៀបរាប់ថាដូចជាបងប្អូនអ៊ុំឬក៏ឪពុកម្ដាយអ៊ុំ ពេលគាត់ជំនាន់ហ្នឹងគាត់ការរស់នៅក៏ដូចជា គាត់មានម៉េចដែរ។ អ៊ុំអាចរៀបរាប់ពីជីវិតរបស់ពួកគាត់ហ៎។

ខ៖ ជីវិតពួកគាត់កាលពីជំនាន់ហ្នឹងអត់មានលំបាកទេអូន នៅតាមអង្គភាពផ្សេងៗចឹងទៅ កូននៅផ្សេង ម្ដាយនៅផ្សេង បងនៅផ្សេងចឹងទៅ អត់លំបាកទេ ។

ក៖ ចាស!

ខ៖ តែរឿងលំបាក ចិត្តមិនដឹងជារឿងរបស់គាត់។

ក៖ ចាស!

ខ៖ លំបាកចិត្តដោះស្រាយរឿងចេះចុះប្អូនអត់ដឹងកាលហ្នឹង។

ក៖ ដោះស្រាយរឿងប្រទេសជាតិឬក៏?

ខ៖ ដោះស្រាយរឿងប្រទេសជាតិ បងប្អូនអ៊ុំអើសុទ្ធតែនេះដែរ ដល់ចឹងទៅគាត់លំបាកចិត្តខាងផ្លូវចិត្តច្រើន ។

ក៖ គាត់ធ្វើអីគេវិញអ៊ំបានគាត់ពិបាកម្ល៉ង់ៗ?

ខ៖ គាត់ដឹកនាំគេ។

ក៖ ចាស!

ខ៖ ដឹកនាំគេប៉ះល្អៗប៉ះអាក្រក់ៗ ចឹងជំនាន់ហ្នឹងវាជូរចត់ទាំងអស់គ្នាដូចអ៊ុំមានពិសោធន៍ចឹងថាមុនមានគេដឹកនាំមុនស្លាប់មួយថ្ងៃមាន១៥នាក់ តែអ៊ំចូលទៅអត់មានស្លាប់ទេ។

ក៖ ហ្នឹងហើយ។

ខ៖ ចង់និយាយថាអ៊ុំដឹកនាំល្អដែរណ៎ា។

ក៖ ចាស! ល្អមែនទែនអ៊ុំ។

ខ៖ ចាស!

ក៖ អរគុណច្រើនសម្រាប់ការនិយាយពីជំនាន់ហ្នឹងដូច ប៉ុន្តែបងប្អូនអ៊ុំស្លាប់នៅក្នុងជំនាន់មួយហ្នឹងទាំងអស់មែនហ៎?

ខ៖ ចាស! ជំនាន់ហ្នឹងទាំងអស់។

ក៖ ហើយអ៊ុំឃើញឥវ៉ាន់ហ្នឹងផ្ទាល់ភ្នែកដែរអ៊ុំហ៎?

ខ៖ យើញផ្ទាល់ភ្នែកតែបងប្អូនតែម្នាក់ទេ។

ក៖ ចាស!

ខ៖ ក្រៅពីហ្នឹង អើយ២នាក់ បងប្រុសមួយ បងស្រីមួយ។

ក៖ ចាស!

ខ៖ តែក្រៅពីហ្នឹងស្លាប់នៅកំពតមួយចឹង ទៅក្បែររោងចក្រនៃស៊ីម៉ង់មួយទៅហ្នំស្លាប់នៅតាកែវមួយទៅ គាត់សុទ្ធតែមានគ្រួសារអស់ហើយជំនាន់ហ្នឹងហ្នំ។

ក៖ ចាស! តែស្លាប់ទាំងប្តីទាំងប្រពន្ធឬក៏ស្លាប់តែម្នាក់ៗឯង?

ខ៖ នៅទេប្រពន្ធហ្នំ ប្រពន្ធគាត់នៅ គាត់ទើបនឹងស្លាប់ឥឡូវៗដែរ។

ក៖ ចាស!

ខ៖ ប្រពន្ធបងទី២ នៅរស់ទេ ប្រពន្ធបងទី២។

ក៖ ចាស! ចឹងអ៊ុំសម្រាប់អ៊ុំរៀបការ រៀបការនៅឆ្នាំប៉ុន្មានវិញ?

ខ៖ ឆ្នាំ៦៩(១៩៦៩)។

ក៖ ១៩៦៩?

ខ៖ ចាស! ឆ្នាំ១៩៦៩។

ក៖ ចាស! ចឹងចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់អ៊ុំវិញម្តង អ៊ុំរៀបការជាមួយអ៊ុំប្រុសដូចជាឆ្នាំ១៩៦៩? ហើយដូចអ៊ុំប្រុសគាត់ឈ្មោះអីគេដែរអ៊ុំ? ប្តីរបស់អ៊ុំហាំ?

ខ៖ គាត់ឈ្មោះនៃ ចក់ ថន។

ក៖ ឥឡូវគាត់អាយុប៉ុន្មានហើយអ៊ុំ?

ខ៖ នៃគាត់អាយុ៦៩ហើយ។

កៈ ចឹងបងអ៊ំ២ឆ្នាំណ្ហោះ?

ខៈ ចាស!

កៈ ចាស! ចឹងបន្ទាប់ពីអ៊ុំរៀបការមក។

ខៈ ៧០ហើយហោ៎ ៧០ហើយគាត់។

កៈ ដល់ពេលអ៊ុំរៀបការហើយតើអ៊ុំមានកូនប្រុសស្រីប៉ុន្មាននាក់ដែរជាមួយអ៊ុំប្រុសចឹងហា៎?

ខៈ កូន៨នាក់មីអូន។

កៈ ចាស! ចឹងអ៊ុំអាចរៀបរាប់ឈ្មោះកូនទាំង៨នាក់ហ្នឹងតើគាត់ឈ្មោះអីគេខ្លះដែរអ៊ុំ?

ខៈ កូនខ្ញុំមីទី១ឈ្មោះ នៃ៎ ធា។

កៈ អ៊ុំអាចប្រាប់ឈ្មោះទាំងត្រកូលហា៎ ឈ្មោះត្រកូលគាត់ពេញចឹងហា៎?

ខៈ ទី១ឈ្មោះនៃ៎ ចីប ធា។ ទី២ឈ្មោះ ចីប ថន ទី៣ឈ្មោះ ចីប ធីម ទី៤ឈ្មោះ ចីប ធឿន ទី៥ឈ្មោះ ចីប ថុល ទី៦ឈ្មោះ ចីប ថា ទី៧ឈ្មោះ ចីប ទូច ទី៨ឈ្មោះ ចីប ឥដ្ឋ។

កៈ ចឹងពីបងមកពីលើដូចជួនៗគ្នា តែដល់ពេលក្រោមៗមកអត់សូវជួនទេថី?

ខៈ វាកើតវាល្អិតពេកដំចេះតែដាក់ឈ្មោះតាមហ្នឹងទៅអូន។

កៈ ចាសៗ!

ខៈ បើតូចដាក់ ឈ្មោះតូចចឹងទៅ។

កៈ ចាស! ហ្នឹងហើយ។ បន្ទាប់ពីអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីហើយស្វាមីអ៊ុំជាមនុស្សប្រុសយ៉ាងម៉េចដែរ? ដូចជានាំក្តីសុខឬក៏អីដែរសម្រាប់ជីវិតរបស់អ៊ុំ?

ខៈ ជីវិតរបស់អ៊ុំអត់មានលំបាកទេអូន។

កៈ ចាស!

ខ៖ ប្តីស្លូតណាស់ ប្តីរាល់ថ្ងៃមិនចេះមាត់ដែរ រហូតដល់សព្វថ្ងៃ។

ក៖ ចាស!

ខ៖ មិនចេះមាត់ទេ។

ក៖ ហ្នឹងហើយ។

ខ៖ កូនក៏មិនចេះវាយ វាយតែម្តាយទេកូន។

ក៖ វាយតែម្តាយម៉េចអ៊ុំ?

ខ៖ ម្តាយវាយកូន ឪពុកមិនដែលវាយកូនទេ។

ក៖ ស្រឡាញ់កូនពេកហោ៎?

ខ៖ ចាស! គាត់ស្លូត ។

ក៖ ចាស!

ខ៖ អត់ចេះប៉ះពាល់ឧបសគ្គអីទេ ប៉ុនអ៊ុំបែកគ្នាយូរហាំណាំ ៦ឆ្នាំហាំ។

ក៖ ម៉េចចឹងវិញ?

ខ៖ គាត់ទៅផ្សេង ខ្ញុំមកផ្សេងយើងអង្គភាពផ្សេងមក។

ក៖ បែកគ្នាពេលជំនាន់ប៉ុលពតហោ៎?

ខ៖ ចាស! ហ្នឹងឯង បែកគ្នាថាតែស្លាប់រៀងខ្លួនហើយ ហើយដល់មកជួបគ្នានៅ៧៩ (១៩៧៩) នេះជួបគ្នារហូត។

ក៖ ចាស! ហើយជួបគ្នានៅឯណាវិញអ៊ុំ?

ខ៖ ជួបគ្នារត់ទៅ ជួបគ្នានឱរ៉ាល់ ភ្នំឱរ៉ាល់ខ្ពស់ហ្នឹង។

ក៖ ចាស! ហើយឃើញគ្នាដំបូងដូចជាម្ខាងៗសង្ស័យថាស្លាប់រាងៗខ្លួនអស់ហាំមែនទេ? ដល់ពេលជួបគ្នាដំបូងមានអារម្មណ៍ម៉េចដែរអ៊ុំដល់ពេលជួបគ្នាចឹង?

ខ៖ អ៊ុំអត់មានភ័យខ្លាចអី អត់មានភ័យភិតអីទេ ជួបគ្នាធម្មតា ព្រោះយើងធ្លាប់បែកគ្នា៦ឆ្នាំទៅហើយ។

ក៖ ចាស!

ខ៖ ដល់ជួបគ្នាវិញចឹងទៅធម្មតាៗ។

ក៖ រំភើបទេពេលហ្នឹង?

ខ៖ អត់មាន! អាពេលជួបហ្នឹងឮអ៊ំនិយាយថាពីមុនមកអ៊ំនៅអង្គភាពផ្សេងចឹងបានគាត់ទៅយកអង្គភាពនារីហ្នឹង។

ក៖ ចាស!

ខ៖ ហ្នឹងហើយជួបគ្នាចាប់តាំងពីពេលដែលគាត់ទៅយករហូតមក។

ក៖ ចឹងដឹងដែរហ៎?

ខ៖ ចាស! ដឹង ដឹងថាខ្ញុំនៅកន្លែងណា។

ក៖ ចឹចឹងបានមករកឃើញ?

ខ៖ ចាស! មករកឃើញ។

ក៖ ចាស! ចឹងអ៊ុំសម្រាប់កូនចៅរបស់អ៊ុំបានឱ្យគាត់សិក្សាទៅចូលរៀនបានគ្រប់គ្នាអីអត់?

ខ៖ កូនអ៊ុំសិក្សានៅតែ២នាក់ទេ អាមុនៗគេនេះអស់ហើយ ជំនាន់ហ្នឹងថ្នាក់ទី៥អីវាជ្រៅជ្រះអីដែរណា៎។

ក៖ ចាស!

ខ៖ តែនៅអាពៅហើយបងវាហ្នឹងនៅរៀនចប់ហើយ។

កៈ ចាស!

ខៈ នៅអាពៅមួយរៀនមួយឆ្នាំទៀត។

កៈ ចាស!

ខៈ ចប់ហើយ ថ្នាក់នែ៎ ឆ្នាំទី៣ហើយ ឆ្នាំនេះ តែ មួយឆ្នាំទៀតចប់ហើយ។

កៈ ចឹងអ៊ុំមូលហេតុអីបានអ៊ុំឱ្យកូនទៅសិក្សា ថាការសិក្សាមានសារៈសំខាន់ម៉េចដែរ?

ខៈ អ៊ុំនឹកឃើញថាម្ដាយឪពុកនេះ វាមិនបានរៀនជិតដល់ចប់ចុងចប់ដើមទេណា ព្រោះម៉ែឪវាក្រ។

កៈ ចាស!

ខៈ ចឹងជីវិតរបស់កូនមានអីចែកទេ មានតែរៀនសូត្រឲ្យចប់ទៅជួយកូនអោយចប់ទៅ។

កៈ ចាស!

ខៈ មានអីចែកកូនទេ មានតែចែកហ្នឹងឯង។

កៈ ចែកចំណេះ។

ខៈ ចែកចំណេះហ្នឹងហើយ ផ្ដល់ឱ្យវារកស៊ីទៅមុខទៀត។

កៈ ចាស! ចឹងអ៊ុំសម្រាប់រាល់ថ្ងៃអ៊ុំប្រកបមុខរបរចិញ្ចឹមជីវិតអីគេដែរ?

ខៈ អ៊ុំរាល់ថ្ងៃមានអី រាល់ថ្ងៃធ្វើដីប៉ុន្មាន២ហិចតាហ្នឹង។

កៈ ២ហិចតា ដាំអីគេដែរអ៊ុំ?

ខៈ ដាំពោត ដាំដំឡូង។

កៈ ចាស!

ខៈ ដាំដំឡូង១ហិចតា ពោត១ហិចតា។

កៈ មួយឆ្នាំៗទទួលបានទិន្នផលខ្ពស់ទេអ៊ុំ?

ខៈ និយាយទៅអ៊ុំដីតិចមែនតែធ្វើអត់មានជំពាក់គេទេ ធ្វើតាមលទ្ធភាពបានប៉ុន្មានយកប៉ុណ្ណឹង អត់មានថាចងការអង្គការអីយកមកលោតលន់ចង់ជួលដីគេអត់ទេ   ធ្វើរបស់ខ្លួនឯងបានប៉ុន្មាន ហ្វបប៉ុណ្ណឹង។

កៈ ចាស!

ខៈ តាមដំណើររបស់អ៊ុំ។

កៈ   ហើយពេលទទួលប្រមូលផលដំឡូងមួយឆ្នាំៗចឹងហ៉ាអ៊ុំ   ដំឡូងបានតម្លៃខ្ពស់អត់ឬក៏ធ្លាក់ចុះអីហេ៉?

ខៈ ដំឡូងឆ្នាំនេះធ្លាក់ចុះនៅ១រៀលមិនដល់១រៀលផង។

កៈ មួយគីឡូ១០០?

ខៈ មួយគីឡូ១០០ខ្មែរហ្នឹងមិនដល់បានផង ជូនអី៩កាក់។

កៈ អូយ! ហើយចុះបើពេលកើនឡើងខ្ពស់ម៉ងប៉ុន្មានរយ?

ខៈ បើកើនឡើងខ្ពស់នៃ ២រៀល(២០០) នៅដីនៅក្នុងដី២០០។

កៈ ចាស! តែមានបានកាប់ដំឡូងហ្នឹងហាលទេអ៊ុំ?

ខៈ អ៊ុំកាលពីឆ្នាំទៅមិញកាប់។

កៈ ហើយដល់ពេលកាប់លក់ទៅបាន១គីឡូប៉ុន្មាន?

ខៈ លក់បាន១គីឡូ៤រៀល(៤០០) ៤រៀលចុច៧។

កៈ ចឹង៤០០ចុច៧០សេនខ្មែរយើងហ្នឹង?

ខៈ អើៗ! ហ្នឹងឆ្នាំទៅមិញ ឆ្នាំនេះអត់បានទេ។

កៈ ចឹងអ៊ុំតម្លៃមួយហ្នឹងខ្ពស់ខ្លាំងអត់?

ខៈ តម្លៃហ្នឹងវាដូចថាពីឆ្នាំមួយទៅឆ្នាំមួយ ដូចថារក្សាបានប៉ុណ្ណឹងវាក៏ល្អដែរ ប៉ុន្តែឆ្នាំនេះចុះហា៎។

កៈ ចាស!

ខៈ ចុះតម្លៃច្រើនហា៎។

កៈ ហើយមួយឆ្នាំរកបានទិន្នផលប៉ុន្មានតោនដែរអ៊ុំ?

ខៈ អ៊ុំខ្លួនឯងបានច្រើនដែរ ១០តោនជាង ចម្ការតែ១ហិចតាហ្នឹងទេណា៎។

កៈ អូ! ច្រើនផង។

ខៈ តែមួយហិចតាហ្នឹងទេបាន១០តោន ១១តោន ។

កៈ ចាស!

ខៈ ជួនធ្វើល្អដាក់ដាំឱ្យសព្វដីទៅបាន៨តោនអីចឹងទៅ។

កៈ មួយហ្នឹងពេលស្ងួនឬក៏ពេលនេះ ៨តោនហ្នឹងពេលវាស្ងួត?

ខៈ ពេលវាស្ងួតហើយ។

កៈ បើអត់ទាន់ស្ងួតហេ៎អ៊ុំ?

ខៈ អត់ស្ងួតអាច៣០ទៅ៤០តោន អាហ្នឹងលក់ស្រស់។

កៈ ចាស! ចឹងបានទិន្នផលខ្ពស់ៗដោយសារដីនៅនេះវាល្អហា៎។

ខៈ ចាស! ដីល្អហើយយើងកាប់យើងអត់សូវចំណាយកម្លាំងច្រើនទេ យើងកាប់ខ្លួនយើង។

កៈ ចឹងកូនចៅជួយទៅអ៊ុំហ្ន៎?

ខៈ កូនចៅខ្លះទៅ យើងជួលគេម្នាក់ ឬពីរនាក់ចឹងទៅណាចេះតែធ្វើទៅណា។

ក៖ ចាស! ហ្នឹងហើយ។ ចឹងអ៊ុំចង់សួរសំណួរមួយទៀតថា តើជីវិតរបស់អ៊ុំហាដូចថាជីវិតដែលសប្បាយជាគេបំផុតនៅពេលណាដែរ?

ខ៖ ហ៊ឺ! អ៊ុំមិនដែលសប្បាយទេអូន។ បើពិនិត្យជីវិតទៅ បើខ្វល់រហូត បារម្ភពីរឿងបងប្អូនបារម្ភពីកូន កូនយើងច្រើនរកស៊ីចិញ្ចឹមមិនទាន់ រកស៊ីឱ្យបានកូនមិនហូបគ្រប់គ្រាន់ យើងគិតរហូតហ៎ា។

ក៖ ចាស!

ខ៖ យកដៃរគ្រាប់ពោតមកជឹងដៃរដាំបានមិនបាន យើងគិតរហូត ដ៏ចឹងបារម្ភអត់នេះទេ អត់នឹងនរទេ ដូចរាល់ថ្ងៃហ្នឹងចឹង។

ក៖ ចាស!

ខ៖ កូនទៅរៀនឆ្ងាយណាស់ បារម្ភកូនចេះកូនចុះខ្លាចឡាន ខ្លាចម៉ូតូហ្នឹងឯង នៅទីក្រុងធម្មតាទេ។

ក៖ ចឹងអ៊ុំសម្រាប់ជីវិតរបស់អ៊ុំអ្វី ដែលអ៊ុំចងចាំជាងគេនៅក្នុងជីវិតដែលអ៊ុំអត់អាចបំភ្លេចបានស្អីគេ ព្រឹត្តិការណ៍អីគេអ៊ុំ?

ខ៖ ព្រឹត្តិការណ៍ហ្នឹងវាវែងឆ្ងាយណាស់ហាពិនិត្យទៅ។

ក៖ ម៉េចដែរអ៊ុំ អាចរៀបរាប់ខ្លះៗ?

ខ៖ បងប្អូនគិតតែ បងស្លាប់ក្រោយគេនេះ បងទី៣ ប៉ុនថាវាជូរចត់ណាស់។

ក៖ វាម៉េចដែរជូរចចត់ហ្នឹង?

ខ៖ ដូចថាបងបង្កើតទី៣នេះដូចថាវា ដូចថាគាត់ដឹកនាំល្អចឹងហា មានអ្នកដែលមិនល្អមកប្រឆាំងនឹងយើងហ៎ា ដូចថាយើងធ្វើមេគេ ដូចថាឡើងគ្រើតៗចឹងទៅ ដល់ពេលយើងកំពុងតែឡើង គេក្តិចបណ្តូលហ៎ា និយាយទៅព្រឹត្តិការណ៍ ហ្នឹងដូចចងចាំទុកដែរ។ វាមានអ្នកខ្លះវាខូចចឹងទៅថ្ងៃហ្នឹងអ៊ុំ បងអ៊ុំហ្នឹងទៅនៅឆ្ងាយពីអ៊ុំទេ។ បើនៅជិតក៏អ៊ុំដឹងដែរ ថ្ងៃហ្នឹងគាត់រៀប

អាហារឱ្យប្តី គាត់ទៅហ្នឹង យកទៅដាក់កន្លែងវាអត់មាននរណាចាំ ដល់ពេលពុះឪឡឹកហ្នឹងទៅអាចមាន គេដាក់ថ្នាំហ្នឹងចងចាំទល់រាល់ថ្ងៃ។

ក៖ គេដាក់ថ្នាំពុលក្នុងឪឡឹកហ្នឹង?

ខ៖ ហ្នឹងឯង។

ក៖ សម្លាប់បងអ៊ុំហ្នឹងមែន?

ខ៖ សម្លាប់គាត់ដល់ពេលហូបហើយ ក្អួតទល់ភ្លឺ ដល់ពេលក្អួតចឹងទៅ អើប្រពន្ធគាត់ចង់ឱ្យប្តីរស់ហាំ គាត់ថាកោសខ្យល់ឪ កោសខ្យល់ចាប់កោសខ្យល់ហើយទៅបណ្តោយ ដូចថាវាយើងកំពុងឈាមឡើង ក្អួតមួយយប់ឈាមកំពុងឡើង កោសខ្យល់បាត់ដង្ហើមបណ្តោយ ដឹកដល់ពេទ្យមិនបានប៉ុន្មានផង ដាក់អុកស៊ីសែនហ្នឹងអត់មានឡើង។

ក៖ អ៊ុំអរគុណច្រើនសម្រាប់ការរៀបរាប់ពីជីវប្រវត្តិជីវិតរបស់អ៊ុំចឹងហាំ។

ខ៖ ចាស!

ក៖ ហើយការ សម្ភាសនេះយើងនឹងរក្សាទុកកូនចៅជំនាន់ក្រោយ ឱ្យគាត់បានស្តាប់ និងយល់ពីជីវប្រវត្តិប្រជាជនខ្មែរយើង ហើយចឹងសម្រាប់សំណួរមួយចុងក្រោយ តើអ៊ុំមានពាក្យពេចន៍អីដែលចង់ផ្តែផ្តាំ ទៅកូនចៅអ៊ុំ ឬក៏អ្នកដែលបានស្តាប់ហ្នឹងឱ្យគាត់ជាមនុស្សដើរលើផ្លូវយ៉ាងម៉េចដែរចឹងហា អ៊ំមានពាក្យអីផ្តែផ្តាំគាត់ហា?

រ: ញ៉ុមថាចង់ផ្តែផ្តាំដែរកូនចៅញ៉ុមថាអត់ឲ្យមាន ទោះបីមានព្រឹត្តិការណ៍ធំដុំម៉េចក៏ដោយក៏យើងកុំប្រឆាំងនឹងគេ សុំតែមួយសុខទៅកូន កុំដើរបង្ករឿងអី ប៉ះពាល់ដល់បងប្អូនណាឲ្យសោះ ទោះបីយើងមានកំហឹងឈឺចាប់ពីកាលណាក៏ដោយក៏យើងសាបសូន្យទៅ អត់មានអោយបន្តទៅទៀតទេ ប្រាប់កូនរាល់ថ្ងៃហ្នឹងហ៎ អត់ចង់ឱ្យមានឈាមសងឈាមអីទៀតទេឱ្យចប់ត្រឹមហ្នឹងទៅ រក្សាឱ្យល្អយើងរស់បានយូរ ចង់និយាយជាមួយកូនប៉ុណ្ណឹងអូន។

ក៖ ចាស! ហ្នឹងហើយ ចឹងអរគុណច្រើនណាអ៊ុំ ។

ខ៖ ចាស៕